**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០៥/០៨ របក.អគគ**

## របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំខែ មករា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មករា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួន ស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ២០០៨

-លិខិតស្នើបញ្ជូនមន្ត្រី ៣ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី “Training Program for Young Leader for Asian Countries for Fiscal Year 2007 ” ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ នៅប្រទេសជប៉ុន

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការបន្ត ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨

-លិខិតស្នើសុំការផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីលក្ខន្តិក:ចៅក្រម និងព្រះរាជ-អាជ្ញានៃព្រះរាជាណាចក្រកម្ពុជា

**ខ. ការងារកំណែទម្រង់**

-ប្រជុំក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករនិងការតាមដានកំណែទម្រង់ច្បាប់និងតុលាការ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ២០០៨

-ប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ បន្ត នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨

-ចុះជួបក្រសួងយុត្តិធម៌ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៨ និងក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៨ ដើម្បីជម្រាបជូនពីការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-ចូលរួមប្រជុំក្រុមប្រឹក្សាគ្រប់គ្រងគម្រោង CCJAPIII នៅសណ្ឋាគារ HIMAWARI នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៨។

**គ. ផ្សេងៗ**

-ទទួលជួបក្រុមការងារ USAID ស្វែងយល់ពីកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៨

## ២-សន្និដ្ឋាន

ក្នុងខែ មករា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការចំនួនពីរលើក ដោយបានឯកភាពគ្នាទៅលើគោលការណ៍ចំបងៗសម្រាប់រៀបចំសូចនាករ និងការតាមដាន។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-គ្រោងរៀបចំប្រជុំ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨ ដើម្បីពិនិត្យរបាយការណ៍ប្រចាំឆ្នាំ ២០០៧ និងទិសដៅសម្រាប់ឆ្នាំថ្មី។

-រៀបចំប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញ ការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យ ស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន ដោយពិភាក្សា ជាមួយ UNDP ដើម្បីឱ្យបន្តជំនួយឧបត្ថម្ភលើគម្រោងនេះ

-ពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស (DIHR) អំពីកិច្ចសហការរវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង និងវិទ្យាស្ថានដាណឺម៉ាកដើម្បីសិទ្ធិមនុស្សសម្រាប់ឆ្នាំ ២០០៨

-ពិភាក្សាបន្តកិច្ចសហប្រតិបត្តិការជាមួយ DANIDA និង CCJAPIII ក្នុងការឧបត្ថម្ភកំណែទម្រង់ច្បាប់ និងតុលាការសម្រាប់ ២ ឆ្នាំទៅមុខទៀត។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង